**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តកំពង់ធំ**

លេខ៖ ៥៣៤៦/១៨ ស.ជ.ណ

ថ្ងៃអង្គារ ១៣កើត ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
កំពង់ធំ ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៨

# សេចក្តីជូនដំណឹង

## ស្តីពីការធ្វើអាជីវកម្មពិឃាតសត្វ និងប្រមូលទិញសត្វក្នុងខេត្ត សម្រាប់ឆ្នាំ២០១៩

**យោង** ៖ - ច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ ចុះថ្ងៃទី ២៨ ខែមករា ឆ្នាំ ២០១៦

- យោងអនុក្រឹត្យលេខ១០៨ អនក្រ.បក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វ
- យោងអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៣ ស្តីពីការត្រួតពិនិត្យ អនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ

រដ្ឋបាលខេត្តកំពង់ធំ សូមជម្រាបជូនដំណឹងដល់សាធារណៈជន និងអាជីវករដែលបាននិងកំពុងប្រកបអាជីវកម្មពិឃាតសត្វ និងប្រមូលទិញសត្វក្នុងខេត្តកំពង់ធំ ទាំងអស់ឲ្យបានជ្រាបថា៖ លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មក្នុងឆ្នាំចាស់នឹងត្រូវអស់សុពលភាពនៅថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ២០១៨ ខាងមុខនេះហើយ ។ ដូច្នេះសម្រាប់ការធ្វើអាជីវកម្មបន្តក្នុងឆ្នាំ២០១៩ រដ្ឋបាលខេត្តកំពង់ធំ សូមប្រកាសជូនដំណឹងអំពីនីតិវិធី និងបែបបទក្នុងការដាក់ពាក្យសុំធ្វើអាជីវកម្ម មានដូចខាងក្រោម ៖

I. លក្ខខណ្ឌនៃការធ្វើអាជីវកម្ម

១-ពលរដ្ឋគ្រប់រូប (លើកលែងមន្ត្រីរាជការ, សិស្ស, និស្សិត, ពិរុទ្ធជន) ដែលមានអាយុចាប់ពី ១៨ឆ្នាំឡើងទៅ គឺអាចមានសិទ្ធិដាក់ពាក្យសុំធ្វើអាជីវកម្មបានស្របតាមនីតិវិធីច្បាប់

២-ការធ្វើអាជីវកម្មមានរយៈពេល ០១ឆ្នាំ គិតពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

៣-ការធ្វើអាជីវកម្មសត្វក្នុងខេត្ត ត្រូវមានលិខិតអនុញ្ញាតចេញដោយអង្គភាពច្រកចេញចូលតែមួយខេត្ត

៤-អាជីវករដាក់ពាក្យសុំធ្វើអាជីវកម្មពិឃាតសត្វ ត្រូវភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់ទីតាំងសម្រាប់លក់សាច់ដែលទទួលស្គាល់ និងអនុញ្ញាតពីអាជ្ញាធរឃុំ/សង្កាត់ និងក្រុង/ស្រុក

៥-អាជីវករដែលទទួលបានលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្ម ត្រូវតែគោរព និងអនុវត្តឱ្យបានត្រឹមត្រូវតាមកិច្ចសន្យាស្តីពីការធ្វើអាជីវកម្មរបស់ខ្លួន។

II. សំណុំបែបបទដែលត្រូវបំពេញ (មានគំរូ)

| | |
|---|---|
| ១-ពាក្យសុំលិខិតអនុញ្ញាតធ្វើអាជីវកម្មពិឃាតសត្វ ឬប្រមូលទិញសត្វ | ចំនួន ០២ ច្បាប់ |
| ២-ប្រវត្តិរូបសង្ខេបមានបិទរូបថតទំហំ ៤x៦ ដោយមានចុះទិដ្ឋាការពីមេឃុំ/ចៅសង្កាត់ | ចំនួន ០២ ច្បាប់ |
| ៣-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬ សៀវភៅគ្រួសារ(ថតចម្លង) | ចំនួន ០២ ច្បាប់ |
| ៤-កិច្ចសន្យាស្តីពីការធ្វើអាជីវកម្មពិឃាតសត្វ ឬប្រមូលទិញសត្វ | ចំនួន ០២ ច្បាប់ |
| ៥-ប័ណ្ណពន្ធប៉ាតង់ឆ្នាំ២០១៨ ចំពោះអាជីវករចាស់ (ថតចម្លង) | ចំនួន ០២ ច្បាប់ |
| ៦-រូបថតថ្មី ទំហំ ៤x៦ (ថតចំពីមុខឥតពាក់វ៉ែនតា) | ចំនួន ០២ សន្លឹក |

III. ទីកន្លែងផ្តល់ពាក្យស្នើសុំ

សាធារណជន និងអាជីវករទាំងអស់ដែលមានបំណងចង់ប្រកបអាជីវកម្ម ឬបន្តនូវអាជីវកម្មរបស់ខ្លួន ត្រូវមកទំនាក់ទំនងដោយផ្ទាល់នៅអង្គភាពច្រកចេញចូលតែមួយខេត្តកំពង់ធំ ដែលមានទីតាំងស្ថិតនៅក្នុងបរិវេណសាលាខេត្តកំពង់ធំ ដើម្បីទទួលបានព័ត៌មានលំអិតអំពីការបំពេញបែបបទដាក់ពាក្យសុំ និងលក្ខណៈវិនិច្ឆ័យដែលនឹងត្រូវទទួលបានសិទ្ធធ្វើអាជីវកម្មពិឃាតសត្វ ។

IV. កាលបរិច្ឆេទផ្តល់ និងឈប់ទទួលពាក្យ

ពាក្យស្នើសុំនឹងត្រូវចែកជូនចាប់ពីថ្ងៃជូនដំណឹងនេះតទៅរហូតដល់ ថ្ងៃទី២០ ខែ ធ្នូ ឆ្នាំ២០១៨ វេលាម៉ោង១៧,៣០នាទីគត់ ដែលជាកាលបរិច្ឆេទចុងក្រោយនៃការឈប់ទទួលពាក្យ ។

អាស្រ័យហេតុនេះសូមសាធារណជន និងអាជីវករទាំងអស់ មកទំនាក់ទំនងយកពាក្យសុំនៅរៀងរាល់ម៉ោងធ្វើការ ចាប់ពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកចាប់ពីម៉ោង ៧:៣០-១២:០០ នាទី និងពេលរសៀលចាប់ពីម៉ោង ១៤:០០-១៧:៣០ នាទី ។

ទទួលបានសេចក្តីជូនដំណឹងនេះ សូមសាធារណជនទាំងអស់ជ្រាបជាព័ត៌មាន ។

ព័ត៌មានបន្ថែមសូមទំនាក់ទំនងតាមទូរស័ព្ទលេខ ០១៧ ២៦១ ៩១៣, ០៧១ ៨ ៩៩៩៩ ៣៦ ។

**អភិបាល**

សុខ~លូ

**ចម្លងជូន៖**

- ក្រសួងមហាផ្ទៃ
- ក្រុមប្រឹក្សាខេត្ត
  «ដើម្បីជូនជ្រាប»
- សាលាក្រុង ស្រុក ទាំង៨
- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
  «ដើម្បីសហការផ្សព្វផ្សាយ និងអនុវត្ត»
- ឯកសារ-កាលប្បវត្តិ